ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

លេខ......០០១........អ.ស.ហ.ប្រក

# ប្រកាស
# ស្តីពី
# សេវាសាធារណៈរបស់និយ័តករគណនេយ្យនិងសវនកម្ម

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
## និងជា ប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤៨៥ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៤១៦/០០៦ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី២ ខែសីហា ឆ្នាំ២០១៩ ស្តីពីការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃស្ថាប័នវិជ្ជាជីវៈគណនេយ្យ និងសវនកម្ម



អគារ១៦៨F ផ្លូវលេខ ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (+៨៥៥) ២៣ ៩៩៩ ៧០០
#168F, Street 598, Sangkat Chrang Chamres 1, Khan Russei Keo, Phnom Penh, Cambodia
Phone: (+855) 23 999 700

- បានឃើញអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញបទបញ្ជាលេខ០៤ បប. ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ របស់រាជរដ្ឋាភិបាលស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញប្រកាសលេខ ០២០ អ.ស.ហ.ប្រក ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២១ ស្តីពីការកំណត់ប្រភព និងការគ្រប់គ្រងធនធានហិរញ្ញវត្ថុរបស់និយ័តករគណនេយ្យនិងសវនកម្ម
- យោងតាមតម្រូវការចាំបាច់របស់និយ័តករគណនេយ្យនិងសវនកម្ម

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-**

ប្រកាសនេះមានគោលបំណងកំណត់ប្រភេទសេវាសាធារណៈ កម្រៃសេវាសាធារណៈ បែបបទ នីតិវិធី និងការចាត់ចែងចំណូលពីសេវាសាធារណៈរបស់និយ័តករគណនេយ្យនិងសវនកម្ម ប្រកបដោយតម្លាភាព និងគណនេយ្យភាព ដើម្បីធានាប្រសិទ្ធភាព និងសក្តិសិទ្ធភាព នៃកិច្ចដំណើរការរបស់ **ន.គ.ស.**។

## ជំពូកទី២

## ប្រភេទសេវាសាធារណៈ និងកម្រៃសេវាសាធារណៈ

**ប្រការ ២.-**

ប្រភេទសេវាសាធារណៈ និងកម្រៃសេវាសាធារណៈ របស់ **ន.គ.ស.** ត្រូវបានកំណត់ដូចខាងក្រោម ÷

| ល.រ | បរិយាយ | កម្រៃសេវា | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| ១ | លិខិតអនុញ្ញាតផ្លាស់ប្តូរការិយបរិច្ឆេទគណនេយ្យ | ១,០០០,០០០ រៀល | ៣០ថ្ងៃ | រហូតមានការអនុញ្ញាតថ្មី |
| ២ | លិខិតអនុញ្ញាតបដិប្បញ្ញត្តិដាក់របាយ-ការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យ | ១,០០០,០០០ រៀល | ៣០ថ្ងៃ | តែ១លើក |
| ៣ | លិខិតស្នើសុំពន្យារការបញ្ចប់ការងារសវនកម្មឯករាជ្យ | ២០០,០០០ រៀល | ១៥ថ្ងៃ | តែ១លើក |

| | | | | |
|---|---|---|---|---|
| ៤ | សេវាទទួលរក្សាទុករបាយការណ៍ហិរញ្ញវត្ថុ | | | |
| | ៤.១. ក្រុមហ៊ុនជាប់កាតព្វកិច្ចដាក់របាយ-ការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យ | ៣០០,០០០ រៀល | ៣០ថ្ងៃ | ១ឆ្នាំ |
| | ៤.២. ក្រុមហ៊ុនមិនជាប់កាតព្វកិច្ចដាក់របាយ-ការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យ | ២០០,០០០ រៀល | ៣០ថ្ងៃ | ១ឆ្នាំ |
| | ៤.៣. អង្គភាពមិនស្វែងរកប្រាក់ចំណេញជាប់កាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យ | ១០០,០០០ រៀល | ៣០ថ្ងៃ | ១ឆ្នាំ |
| | ៤.៤. អង្គភាពមិនស្វែងរកប្រាក់ចំណេញមិនជាប់កាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យ | ៦០,០០០ រៀល | ៣០ថ្ងៃ | ១ឆ្នាំ |
| ៥ | សេវាប្រឹក្សាយោបល់លើការប្រកបវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម | ២០០,០០០ រៀល ក្នុងមួយម៉ោង | ភ្លាម | ១លើក |
| ៦ | សេវាប្រឹក្សាលើវិវាទក្នុងនាមជាអ្នកសម្របសម្រួល | ១០០,០០០ រៀល ក្នុងមួយម៉ោង | ភ្លាម | ១លើក |
| ៧ | លិខិតស្នើសុំបញ្ជាក់បច្ចុប្បន្នភាពព័ត៌មានសហគ្រាស | ២០០,០០០ រៀល | ៣០ថ្ងៃ | ១លើក |

## ជំពូកទី៣

## ការផ្សព្វផ្សាយ និងការផ្តល់សេវាគាំទ្រ

**ប្រការ ៣.-**

**ន.គ.ស.** ត្រូវបិទផ្សាយ ឬផ្សព្វផ្សាយជាសាធារណៈនូវប្រកាសនេះ នៅនឹងកន្លែងផ្តល់សេវា ឬតាមបណ្តាញព័ត៌មានពិសេស នៅច្រកចេញ-ចូលតែមួយ។

**ន.គ.ស.** ត្រូវរៀបចំទីកន្លែងផ្តល់សេវាដែលមានលក្ខណៈជាច្រកចេញ-ចូលតែមួយ និងមានមន្ត្រីប្រចាំការនៅទីកន្លែងដែលបានកំណត់ជាក់លាក់ ដើម្បីទទួលបម្រើសេវាជូនសាធារណជនឱ្យបានទាន់ពេលវេលាតាមការកំណត់។

**ន.គ.ស.** ត្រូវរៀបចំឱ្យមានកន្លែងទទួលបណ្តឹងតវ៉ា ដែលអាចកើតមានឡើងជាយថាហេតុ ជាពិសេស ក្នុងករណីមានការអនុវត្តខុសពីស្តង់ដាសេវា ឬមានការយកថ្លៃសេវាលើសការកំណត់ ឬមានការយឺតយ៉ាវជាដើម។

## ជំពូកទី៤
## ការគ្រប់គ្រងចំណូលពីសេវាសាធារណៈ

**ប្រការ ៤.-**

**ន.គ.ស.** មានភារកិច្ចប្រមូល គ្រប់គ្រង និងចាត់ចែងចំណូលពីសេវាសាធារណៈដែលប្រមូលបាន ស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

**ប្រការ ៥.-**

**ន.គ.ស.** ត្រូវរៀបចំរបាយការណ៍ស្តីពីការអនុវត្តចំណូលពីសេវាសាធារណៈប្រចាំខែ និងប្រចាំឆ្នាំ ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សា **អ.ស.ហ.** ឱ្យបានមុនថ្ងៃទី១០ នៃខែបន្ទាប់ សម្រាប់របាយការណ៍ប្រចាំខែ និងឱ្យបានមុនថ្ងៃទី១៥ ខែមករា នៃឆ្នាំបន្ទាប់ សម្រាប់របាយការណ៍ប្រចាំឆ្នាំ។

**ប្រការ ៦.-**

ប្រភេទសេវាសាធារណៈ និងកម្រៃសេវាសាធារណៈ បានកំណត់នៅក្នុងប្រការ២ នៃប្រកាសនេះ អាចកែប្រែបានតាមការចាំបាច់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សា **អ.ស.ហ.**។

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**ប្រការ ៧.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៨.-**

អគ្គលេខាធិការនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ អគ្គនាយកនៃនិយ័តករគណនេយ្យនិងសវនកម្ម អគ្គនាយកនៃនិយ័តករ ប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ និងបុគ្គលពាក់ព័ន្ធត្រូវទទួលអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃពុធ ១០ កើតខែ បុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ មករា ឆ្នាំ២០២២

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជា**
**ប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ**

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល:**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ឯកឧត្តមនិងលោកជំទាវជាអនុប្រធាន និងសមាជិកក្រុមប្រឹក្សា-អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
  “ដើម្បីជូនជ្រាប”
- ដូចប្រការ ៨
  “ដើម្បីអនុវត្ត”
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ